ឯរណ្តៅសាកសពនិងចំនួនសាកសព សុខខៃ បានប្រាប់ដូចដែលលោកមេឃុំ គឹង យ៉ាតបានប្រាប់ដែរ ។ ប៉ុន្តែ សុខខៃ បន្ថែមថារណ្តៅធំៗចំនួនបី ទំហំទទឹង២ម៉ែត្រ និង បណ្តោយ៣០ម៉ែត្រនៃរណ្តៅមួយៗ ជីកតាមបណ្តោយគុម្ពឬស្សី ជ្រុងខាងលិចបរិវេណចំការស្វាយចន្ទី ដោយទុកចន្លោះពីរណ្តៅមួយទៅរណ្តៅមួយទៀតប្រហែល៥ម៉ែត្រ ។ ជនរងគ្រោះដែលបានស្លាប់ក្នុងរណ្តៅនោះមានប្រមាណពី៥០០០-៧០០០នាក់ ។ ចំណែករណ្តៅគ្រាប់បែកមានបី ដែលមួយៗមានអង្កត់ផ្ចិតប្រហែល៥-៦ម៉ែត្រ ជំរៅ២ម៉ែត្រ (តាមសំដីគឹង យ៉ាតថាមានអង្កត់ផ្ចិត១០ម៉ែត្រ និងជំរៅ១,៥ម៉ែត្រ) ។ មានមនុស្សស្លាប់ជាង២០០នាក់ ។ មនុស្សដែលបានស្លាប់នៅក្នុងរណ្តៅគ្រាប់បែក ជាកងចល័តរបស់ខ្មែរក្រហម ។ ពួកកងចល័តទាំងនោះ ត្រូវបានពួកខ្មែរក្រហមយកមកសម្លាប់មុនការសម្លាប់រួមទាំង១៣ភូមិ ក្នុងឃុំស្វាយទាប ។ រណ្តៅគ្រាប់បែកនេះស្ថិតនៅទិសខាងជើងនៃបរិវេណចំការស្វាយចន្ទី (ឆ្ងាយពីរណ្តៅធំប្រហែលជាង១០០ម៉ែត្រ) ។ នៅមានរណ្តៅតូចៗជាច្រើនទៀត ដែលសុខខៃមិនអាចធ្វើការប៉ាន់ស្មានបាន ព្រោះរណ្តៅតូចៗនោះ ត្រូវបានជីក និង សម្លាប់ប្រជាជនដាក់ស្ទើរតែរាល់ថ្ងៃ ។ សម្លាប់ម្តងពី២-៥នាក់ក្នុងមួយរណ្តៅតូចនេះ ។ សុខខៃ ក៏បានធ្វើការប៉ាន់ស្មានរួមនូវចំនួនសាកសពដែលបានស្លាប់ក្នុងចំការស្វាយចន្ទីថាមានចំនួន **ជាងមួយម៉ឺននាក់** ។

ក៏មានការបញ្ជាក់ពី សុខខៃ ដែរថាវិធីសម្លាប់របស់ខ្មែរក្រហមគឺបណ្តើរមនុស្សមកសម្លាប់មានចងស្លាបសេក គ្មានចងមុខ រួចឲ្យលុតជង្គង់នៅមាត់រណ្តៅជាជួរៗ បន្ទាប់មកក៏ចាប់ផ្តើមវាយសម្លាប់ ដោយពួកខ្មែរក្រហមប្រើដែកបំពង់ទឹបសំរាប់វាយសម្លាប់ ។ ដែកនេះមានទំហំធំជាងមេជើងបន្ទិច និង គល់ឬស្សី ។

ការសម្លាប់មនុស្សរបស់ខ្មែរក្រហម បានប្រព្រឹត្តទៅយ៉ាងសាហាវ ដូច សុខខៃ បានរៀបរាប់ពីការសម្លាប់កងចល័តជាង ២០០ នាក់តែក្នុងរយៈពេលមួយថ្ងៃ ហើយសម្លាប់ប្រជាជនទាំង១៣ភូមិ ក្នុងឃុំស្វាយទាប

ក៏ក្នុងរយៈពេលមួយថ្ងៃដែរ ។ មនុស្សដែលត្រូវបានសម្លាប់នៅចម្ការស្វាយចន្ទី មិនមែនជាមនុស្សដែលជាប់នៅក្នុងមន្ទីរសន្តិសុខទេ គឺសុទ្ធតែជាប្រជាជនស្លូតត្រង់ ។

សាកសពទាំងនោះ មិនត្រូវបានលុបដីជិតទាំងស្រុងទេ ។ ក្រោយថ្ងៃរំដោះ១៩៧៩ មានប្រជាជនជាច្រើនបាននាំគ្នាជីកកកាយក្នុងរណ្តៅសាកសពដើម្បីរកមាសពេជ្រផ្សេងៗ ដែលជាហេតុធ្វើឲ្យឆ្អឹងមួយចំនួនត្រូវរប៉ាត់រប៉ាយនៅលើមាត់រណ្តៅ ។ ក្រោយមកទៀតបានរដ្ឋអំណាចឃុំស្វាយទាបប្រមូលដាក់មួយកន្លែងនៅលើមាត់រណ្តៅដោយបានធ្វើជាស្តូបតូចមួយសំរាប់ការពារខ្យល់ ក្តៅ ភ្លៀងអោយអដ្ឋិធាតុទាំងនោះ ។ ប៉ុន្តែក្រោយមកអដ្ឋិធាតុនោះក៏បានយកទៅតំកល់នៅក្នុងវត្តស្វាយទាបជាច្រើនលើកច្រើនសារកន្លងមក អដ្ឋិធាតុទាំងនោះត្រូវបានបាត់បង់អស់ដោយពុំដឹងអំពីមូលហេតុច្បាស់លាស់ ។ សូមបញ្ជាក់ផងដែរ អដ្ឋិធាតុដែលបានប្រមូលនោះមិនបាន១ ៗ១០ នៃឆ្អឹងទាំងអស់ក្នុងចំការស្វាយចន្ទីទេ ។

សុខខៃ ធ្លាប់បានជួប កែ ពក ជាប្រធានភូមិភាគ៣០៤ ឬភូមិភាគកណ្តាល នៅចុងឆ្នាំ១៩៧៧ ពេលដែលគាត់កំពុងបរទេះដឹកអូស ។ ប្រពន្ធរបស់ កែ ពក ឈ្មោះ សឿង ជាគណៈស្រុកចំការលើ ។

បន្ទាប់ពីបានជួប ឡុង សុខខៃ រួច ក្រុមយើងក៏បានទៅជួបជាមួយអ៊ំប្រុស លី ឃិន ។

ឃិន មានអាយុ៥៦ឆ្នាំ ស្រុកកំណើតនៅភូមិស្វាយព្រៃ ឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ បច្ចុប្បន្នអ៊ំប្រុសរស់នៅភូមិវារីលិច ឃុំស្វាយទាប ស្រុកចំការលើ ។ អ្វីដែលអ៊ំប្រុសនិយាយមិនខុសពីអ្វីដែល ឡុង សុខខៃ បាននិយាយទេគឺ ពីឆ្នាំ១៩៧៥ ដល់ខែមិថុនា ឆ្នាំ១៩៧៨ មន្ទីរសន្តិសុខចំការស្វាយចន្ទីបានចាប់មនុស្សមកឃុំឃាំងច្រើនតែប្រភេទអ្នកជាប់និន្នាការនយោបាយតាំងពីជំនាន់សីហនុ, លន់ នល់ អ្នកខ្ជិលច្រអូសមិនមកធ្វើការ និងអ្នកខុសសីលធម៌ ។ អ្នកទោសទាំងនោះត្រូវបានសម្លាប់ចោលទាំងអស់នៅចំការស្វាយចន្ទី បន្ទាប់ពីបានប្រែក្លាយពីមន្ទីរសន្តិសុខទៅជាកន្លែងសម្លាប់ដ៏ធំរួចមក ។ លី ឃិន បន្តថា ប្រជាជនទាំង១៣ភូមិក្នុងឃុំស្វាយទាបត្រូវបានពួកខ្មែរក្រហមសម្លាប់តាំងពីព្រលឹមរហូតដល់ល្ងាច(៥០០០ទៅ៧០០០នាក់) ក្រោមរូបភាពស៊ីជីកសប្បាយពីអ្នកសម្លាប់ និងមានការចាក់មេក្រូយ៉ាងទ្រហឹង ។ ក្នុងចំការស្វាយចន្ទីនេះក៏មានការសម្លាប់អនិកជនយួនផង ។ លី ឃិន និយាយថា ប្រសិនបើជនជាតិវៀតណាមភេទប្រុសរៀបការជាមួយប្រពន្ធខ្មែរ គឺត្រូវខ្មែរក្រហមយកប្តីមកសម្លាប់នៅស្វាយចន្ទីនេះ ហើយប្រសិនបើប្រពន្ធជាវៀតណាមរៀបការជាមួយប្តីខ្មែរ ក៏ត្រូវខ្មែរក្រហមយកប្រពន្ធមកសម្លាប់មុនដែរ ហើយក្រោយមកយកប្តី ប្រពន្ធជាខ្មែរមកសម្លាប់តាមក្រោយ ។

ថ្ងៃទី ២៥-៥-២០០០

វេលាម៉ោង៨ៈ៥៥នាទី ក្រុមដែនទីជួបជាមួយលោក ឈុន ឡា ជាប៉ូលីសស្រុកចំការលើដែលមានទីលំនៅភូមិថ្នល់បែកកើត ឃុំស្វាយទាប ស្រុកចំការលើ ។ ឈុន ឡាបាននិយាយប្រាប់ពីការសម្លាប់មនុស្សនៅចំការស្វាយចន្ទីដល់ក្រុមយើងថាៈ

ថ្ងៃមួយក្នុងខែ៧ ឆ្នាំ១៩៧៨ ឈុន ឡា បានទទួលបញ្ជាពីប្រធានកងអោយដឹកយកមនុស្សពីរនាក់(ប្រជាជនថ្មី) ហៅតា៨០ទៅកាន់(ស្រឡៅពក) ដោយមានទិសដៅឆ្ពោះមកកាន់ទីតាំងសម្លាប់ស្វាយចន្ទី ។ ឡា បានដឹកតា៨០ទាំងពីរនាក់រួមជាមួយរទេះគោ៣០ផ្សេងទៀតក្នុងទិសដៅតែមួយ ។ ពេលធ្វើដំណើរមកជិតដល់កន្លែងសម្លាប់ក៏បានឮសូរសំលេងមេក្រូយ៉ាងទ្រហឹង ព្រមទាំងបានឮសំលេងយំរបស់ក្មេងៗ ។ នៅពេលដែលរទេះបរដល់ផ្លូវបំបែក(ផ្លូវមួយឆ្ពោះទៅ៖ស្រឡៅពក) ផ្លូវមួយទៀតចូលទីតាំងសម្លាប់ស្វាយចន្ទី ឡា បានឃើញសេនាជន(អាយុ១៥-១៦ឆ្នាំ) មួយចំនួនឈរឃាត់ផ្លូវមិនអោយរទេះទាំងនោះធ្វើដំណើរឆ្ពោះទៅ(ស្រឡៅពក)ទេ គឺបានបញ្ជាអោយកងរទេះទាំងនោះបត់ចូលក្នុងទីតាំងសម្លាប់ស្វាយចន្ទី ។ ពេលចូលទៅគៀកនឹងកន្លែងសម្លាប់មែនទែន ឈុន ឡាបានឃើញមេខ្មែរក្រហម២នាក់ក្នុងនោះមានម្នាក់ឈ្មោះ សួនកំពុងតែបញ្ជាអោយសេនាជនចូលទៅចងមនុស្សលើរទេះទាំងប៉ុន្មានយកទៅសម្លាប់ចោល ។ ចំនែកកាបូប វ៉ាលីរបស់ជនរង់គ្រោះត្រូវបានឈុន ឡាលើកគ្រវែងចេញពីរទេះទៅលើពំនូកឥវ៉ាមួយដែលមានកំពស់ប្រហែល៥ម៉ែត្រ តាមសំរែកបញ្ជារបស់ប្រធានកងប្រធានក្រុមនៅកន្លែងនោះ ។ បន្តិចក្រោយមកប្រធានកង, ប្រធានក្រុមទាំងនោះបានស្ទុះទៅលើកឥវ៉ាន់របស់ជនរងគ្រោះដើម្បីយកវត្ថុដែលពួកគេ(ប្រធានកង, ក្រុម) ចាត់ទុកថាជាវត្ថុមានតំលៃដូចជា អាវម៉ុងតេហ្កុយ, សារុងសូត្រ, ខោកាណាដា....ៗល ។ ឈុន ឡា បន្តថាបានឃើញសេនាជា២,៣នាក់ដើរចេញពីមាត់រណ្តៅមកអូសយកជនរងគ្រោះដែលចងួចយកទៅសម្លាប់បន្តទៀត ។ សេនាជនទាំងនោះតាមសំដីរបស់ឈុន ឡា ថាមានកាន់ពូថៅមួយម្នាក់ដែលមានដៃវែង-ដងខ្លី ។ ឈុន ឡា សន្និដ្ឋានថាទំនងសម្លាប់នឹងពូថៅនេះទៅលើជនរងគ្រោះ ។ ចំណែកស្ត្រីមានកូនខ្ចីបីនឹងដៃ ត្រូវពួកសេនាជនចងបន្ទូរដើម្បីទុកដៃបីកូនអោយជៅ ។ ប៉ុន្តែប្រសិនបើស្ត្រីនោះចង់បត់ដៃជើងគឺត្រូវជុះដាក់សារុងដែលកំពុងស្លៀក ហើយត្រូវបានពួកសេនាជនទាំងនោះយកជើងទៅឆ្កឹះគូទស្ត្រីនោះបើសិនបត់ជើងយូរ ។ នេះជាសំដីរបស់ ឈុន ឡា ដែលបាននិយាយទាំងទឹកភ្នែករលីងរលោងប្រាប់យើង ។

ក្រោយមកបានប៉ុន្មានថ្ងៃ ឈុន ឡា ត្រូវបានប្រធានឃុំឈ្មោះយ៉ុនហើយត្រូវជាប្រធានចាត់ចែងនៅទីតាំងសម្លាប់ស្វាយចន្ទីហៅអោយមកប្រជុំនៅម៉ោង ៦ល្ងាចដើម្បីបំផុសកំលាំងអោយចូលរួមកំទេចខ្មាំងជួយគាំទ្របក្សនិងធ្វើឥរិយាបទត្រឹមត្រូវជួយលក្ខ័ការណ៍បក្ស ។ ឈុន ឡា ភ័យស្ទើរលោះព្រលឹងខ្លាចក្រែងខ្មែរក្រហមយកមកសម្លាប់ដោយយកឡេសថាអោយមកប្រជុំ ។ ប៉ុន្តែកិច្ចប្រជុំក្រោមអធិបតេយ្យភាពឈ្មោះ យ៉ុនត្រូវបានបញ្ចប់ហើយអនុញ្ញាតិអោយឈុន ឡាព្រមទាំងមនុស្សជាង២០នាក់ផ្សេងទៀតត្រលប់មកផ្ទះវិញ ។

ចុងបញ្ចប់នៃកិច្ចសំភាសន៍ ឈុន ឡា បានបញ្ជាក់ថាភូមិទាំង១៣ក្នុងឃុំស្វាយទាបត្រូវយកប្រជាជនទៅសម្លាប់នោះគឺភូមិថ្នល់បែកកើត, ថ្នល់បែកលិច, ស្រែពាល, ព្រឹកមហា, ត្រពាំងបេង, អូដារ, ស្វាយទាប, តាំងក្រង, វ៉ារីលិច, វ៉ារីកើត, ត្រម៉ាត់ដី, និងភូមិចិន ។ ក្នុងចំណោមភូមិទាំង១៣នេះមានភូមិមួយគឺភូមិស្រែពាលមិនត្រូវបានសម្លាប់ទាំងអស់ទេ ព្រោះកាលនោះ(ខែ៧, ១៩៧៨) ប្រធានភូមិភាគ៣០៤ឈ្មោះកែ ពកបានមកឃើញរួចក៏និយាយថា៖អ្នកណាអោយសម្លាប់ អ្នកធ្វើអញ្ចឹង៖ នៅពេលដែលកែ ពកបានធ្វើដំណើរកាត់ផ្លូវហ្នឹង

(ផ្លូវជាប់ទីតាំងសម្លាប់ស្វាយចន្ទី) ។ ពេលនោះកែ ពកបានចាប់មេសង្កាត់ឈ្មោះ យ៉ុនយកទៅសម្លាប់ចោលបន្ទាប់ពីពីរថ្ងៃក្រោយការសម្លាប់ដែលមានទ្រង់ទ្រាយធំរួច ។

ឈុន ឡាត្រូវរួចខ្លួនពីសេចក្តីស្លាប់ចុងក្រោយនៅពេលដែលកែ ពកបញ្ជាអោយចុះឈ្មោះអ្នកបេះដឹងទាំងប៉ុន្មានក្នុងភូមិ(ឈុន ឡាក៏មានឈ្មោះដែរ) ប៉ុន្តែពេលនោះ(ចុងឆ្នាំ១៩៧៨) ឈុន ឡាលមាននិយាយម្នាក់ឈ្មោះយាយឃីមដែលជាជំនិតរបស់ប្រពន្ធឈុន ឡាជួយមិនអោយឈុន ឡាកត់ឈ្មោះទេដោយយកឡេសថាត្រូវជាប់សាច់ឈាម ។ ចំនែកអ្នកដែលបានចុះឈ្មោះរួចក៏ត្រូវបានសម្លាប់តាមគំរោងដែនការដែរគឺត្រឹមតែនាំជនរងគ្រោះទាំងនោះដើរមើលរោងចក្រ, ទំនប់កំពង់ថ្ម,....ជំនួសទៅវិញ ព្រោះជិតបែកឆ្នាំ១៩៧៩ហើយ(សម្លាប់មិនទាន់) ។

ក្រោយពីជួបលោកឈុន ឡាយើងបានបន្តដំណើរទៅជួបលោកប្រធានភូមិបែកកើតឈ្មោះហម គឹមសួរ នៅវេលាម៉ោង១០:១៥នាទី ។

ហម គឹមសួរមានអាយុ៥៩ឆ្នាំមានទីលំនៅនៅភូមិថ្នល់បែកកើត ឃុំស្វាយទាប ស្រុកចំការលើ ។ គឹមសួរប្រាប់យើងថាគាត់ជាអ្នកបរទេះដឹកមនុស្សចេញពីភូមិថ្នល់បែកកើតកាលពីជំនាន់ខ្មែរក្រហមជាអ្នកបញ្ជាអោយគាត់ដឹកមនុស្សយកទៅសម្លាប់ ។ ប៉ុន្តែគាត់(គឹមសួរ)ដឹកចេញពីភូមិបានតែ៣០-៤០ម៉ែត្រប៉ុណ្ណោះក៏ត្រូវដឹកបន្តដោយកណៈកង គណៈក្រុមផ្សេងៗទៅកាន់ចំការស្វាយចន្ទី ។ ខាល ឆេងបានឡើងទៅគណៈឃុំជំនួសឈ្មោះយ៉ុនដែលកែ ពកបានបញ្ជាអោយសម្លាប់ ។

យោងតាមសំដីគឹមសួរថាបានឃើញមិត្តអឿន ដែលត្រូវជាប្អូនថ្លៃរបស់កែ ពកដើរចូលទៅក្នុងរោងបាយមួយកន្លែងក្នុងភូមិថ្នល់បែកកើត ។ អឿនបាននិយាយថាហេតុអីបានជានាំគ្នាហូបបាយលាយចេកអញ្ចឹង? ពេលនោះអ្នកនៅក្នុងរោងបាយទាំងអស់នាំគ្នាត្រេតអរណាស់ ព្រោះនឹកស្មានថាថ្ងៃក្រោយប្រាកដជាបានបាយសុទ្ធស៊ីហើយ ប៉ុន្តែផ្ទុយស្រលះក្រោយពេលដែលមិត្តអឿនចេញទៅពីរោងបាយស្រាប់តែមានការកាត់បន្ថយបន្ថែមទៀត មិត្តអឿននិយាយរបៀបនេះនៅឆ្នាំ១៩៧៣-៧៤ ។

សន្និដ្ឋានៈ

ទីតាំងសម្លាប់ចំការស្វាយចន្ទីមានៈ

- រណ្តៅធំស្ថិតនៅទិសខាងលិចក្នុងបរិវេណចំការស្វាយចន្ទី(ទំហំ ២៖៣០ជំរៅ១,៥-២ម៉ែត្រ) ចំនួន៣-៤, ចំលើយជនរងគ្រោះទាំងប៉ុន្មានខាងលើបញ្ជាក់ថាមានមនុស្សស្លាប់ប្រមាណពី៥០០០-៧០០០នាក់ ។
- រណ្តៅគ្រាប់បែកចំនួន៣ស្ថិតនៅខាងជើងក្នុងបរិវេណចំការស្វាយចន្ទីមានទំហំផ្ចិតរង្វង់៦ម៉ែត្រជំរៅ ២ម៉ែត្រ មានមនុស្សស្លាប់ទាំង២០០នាក់សុទ្ធតែកងចល័តខ្មែរក្រហម ។

ចំនែកគំនរខោអាវរបស់ប្រជាជនដែលបានចាញ់បញ្ឆោតខ្មែរក្រហមថាផ្លាស់ប្តូរទីលំនៅហើយត្រូវមកសម្លាប់នៅទីនេះត្រូវពួកខ្មែរក្រហមដុតចោលទាំងអស់ក្រោយពីការឆែកឆេររកមាស, ពេជ្ររួម ។ គំនរដេះក្រោយពីការដុតខោអាវស៊ុម លីបានប្រាប់ថាមានកំពស់ស្មើនឹងទ្រូងមនុស្សចាស់(ជាងមួយម៉ែត្រ) ។

ក្រោយពីបានសាកសួរពត៌មានរួចលោកស៊ឹម លីបានជូនដំណើរក្រុមស្រាវជ្រាវនៅពិនិត្យដល់ទីតាំងឡូ ១៨ ដែលគាត់បានប្រាប់រួចមកហើយ ។ ទៅដល់ទីតាំងយើងពិនិត្យឃើញថាជាក់ស្តែងនូវរណ្តៅមួយចំនួនដែលនៅមានស្នាកស្នាមនៅឡើយ ។ ជាក់ស្តែងនៅរណ្តៅមួយនោះស្ថិតនៅក្នុងចំការកៅស៊ូទើបដាំថ្មី ប៉ែកខាងលិចចំការកៅស៊ូចាស់(ក្នុងឡូ១៨) នៅមានសសសល់ធ្មេញ ឡេវអាវខ្លះៗ ។

ចំពោះការសន្និដ្ឋាននៅលើចំនួនសាកសព, ស៊ុម លី មិនអាចធ្វើការសន្និដ្ឋានបានឡើយ ប៉ុន្តែស៊ឹម លីបាននិយាយថាមនុស្សដែលបានស្លាប់នៅឡូ១៨នេះមានចំនួនច្រើន ព្រោះមកពីបណ្តាលឃុំ ស្រុកនានាក្នុងខេត្តកំពង់ចាម ។ ជាក់ស្តែងពីឆ្នាំ១៩៧៥-១៩៧៧ប្រជាជននៅឃុំស្វាយទាបចំនួន៥០០គ្រួសារក៏បានមកស្លាប់នៅឡូ M-18 នេះដែរ ។

ស្រុកព្រៃឈរៈ (ថ្ងៃទី២៦-៥-២០០០)

១. មន្ទីរសន្តិសុខមិត្ត សុបៈ

ស្ថិតនៅក្នុងភូមិតាកែវ ឃុំគរ ។ មន្ទីរនេះជាមន្ទីរសន្តិសុខតំបន់៤១ក្នុងភូមិភាគកណ្តាលដែលមានអាគារ៤ខ្នងសង់ជាលក្ខណៈសាលារៀន, ដំបូលប្រក់ក្បឿង ជញ្ជាំងក្តារដែលមានទំហំក្នុងមួយខ្នងៗប្រវែង១២ម៉ែត្រ និងទទឹង៦ម៉ែត្រ ។ មន្ទីរនេះគ្រប់គ្រងដោយមិត្តសុប ។ មិត្តសុប មានស្រុកកំណើតនៅឃុំសំរោង ស្រុកព្រៃឈរ ។

បច្ចុប្បន្នមន្ទីរសន្តិសុខដែលមានផ្ទៃដី៦០,១០០នេះក្លាយជាដីកម្មសិទ្ធិរបស់លោកតាហ៊ុលយាយសៀប ។ ក្រោយពីបានទៅពិនិត្យផ្ទាល់ទើបដឹងថាដីនោះ(មន្ទីរសន្តិសុខមិត្តសុប) បានបន្សល់នូវស្រះទឹកចំនួនបីដែលជីកដោយកំលាំងអ្នកទោសកាលពីខ្មែរក្រហមនៅកាន់អំណាច ។ ម៉្យាងទៀតទីតាំងនេះបច្ចុប្បន្នជាកន្លែងមួយដែលមានទួលខ្ពស់ព្រមទាំងមានម៉ុងខ្មោចចិនជាច្រើនផងដែរ ។

នៅលើទួលនៃអតីតមន្ទីរសន្តិសុខមិត្តសុប យើងបានជួបជាមួយលោកពូម្នាក់ដែលជាជំទប់លេខពីឃុំគរឈ្មោះណៃ គឹមសាន់ ។ លោកពូមានអាយុ៥៣ឆ្នាំមានស្រុកកំណើតនៅភូមិតាមាស ឃុំគរ ស្រុកព្រៃឈរ ។ ជំនាន់ប៉ុល ពតនិងបច្ចុប្បន្នលោកពូរស់នៅភូមិនេះដដែល ។ លោកពូបានប្រាប់យើងថាកាលពីជំនាន់ប៉ុល ពតមន្ទីរសន្តិសុខមិត្តនេះដាក់អ្នកទោសភាគច្រើនជាអ្នកជាប់និន្នាការទាហានលន់ ណុល ។អ្នកទោសទាំងនោះត្រូវបានសម្លាប់ដោយពួកអ្នកយាមគុកដោយប្រើដំបងឈើ ដែកជាឧបករណ៍សម្លាប់ ។ ចំនែកការហូបចុកវិញលោកពូណៃ គឹមសាន់ប្រាប់ថាគ្មានចាននិងស្លាបព្រាសំរាប់បរិភោគបាយទេគឺដាក់នឹងស្លឹកចេកអោយបរិភោគ ថែមទាំងមិនបានដោះខ្នោះចេញទៀតផង ។ អ្នកទោសទាំងអស់តំរូវអោយដាក់ខ្នោះជាប់ជារៀងរាល់ថ្ងៃ ។ ប្រសាសន៍របស់លោកពូបាន

បន្តថា ខ្នោះដែលដាក់អ្នកទោសនោះមិនមែនជាខ្នោះដែកទេ គឺជាខ្នោះឈើដែលមានទំហំ៥៖១៥ហ៊ុនហើយចោះប្រហោងសំរាប់ដាក់កជើង រួចមានបន្ទះឈើមួយទៀតដែលមានទំហំល្មមគ្របពីលើរួចចាក់សោរមិនអោយជើងចេញបាន ។ ទាំងពេលបាយ, ពេលបត់ជើង, ពេលដេកគឺមិនត្រូវបានដោះខ្នោះចេញឡើយ, តាមសំដីរបស់លោកពូគឹមសាន់ថាអ្នកទោសទាំងអស់គ្មានគ្រែសំរាប់ដេកទេ(ដេកផ្ទាល់នឹងដី) ហើយពេលបត់ជើងធំម្តងៗ គឺមានពងតូចមួយល្មមម្នាក់មួយសំរាប់ដាក់លាមកខ្លួនឯងដោយគ្រាន់តែរំកិលគូទដាក់អោយចំមាត់ពាងដែលស្ថិតនៅក្បែរខ្លួនទៅជាការស្រេច ។

ក្នុងមន្ទីរសន្តិសុខមិត្តសុបនេះមិនដែលមានការប្រជុំឬបំពាក់បំប៉នអ្វីដល់អ្នកទោសឡើយក្រៅពីចេញទៅធ្វើការនៅម៉ោង៧ព្រឹក អ្នកទោសទាំងអស់ត្រូវដេកជាប់ខ្នោះនៅមួយកន្លែង ។ លោកពូណៃ គឹមសាន់ បន្តថាអ្នកទោសដែលជាប់ក្នុងមន្ទីរនេះគ្មាននរណាម្នាក់អាចរួចខ្លួនបានទេគឺត្រូវសម្លាប់ទាំងអស់ រួចសែងយកទៅកប់នៅតាមកន្លែងមួយចំនួនដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីបរិវេណមន្ទីរសន្តិសុខនេះ ដូចជានៅទីតាំងទួលក្រសាំង, ត្នោតជួរ, អូរតាគង់និងទួលដើមអំពិល ។

២. ទីតាំងសម្លាប់ៈ

ក. អូតាគង់ៈ

ជាអូរឬប្រឡាយទឹកមួយដែលលាតសន្ធឹងពីភូមិតាមាសដល់ស្ទឹងទឹឆាមានប្រវែងប្រហែល១០០០ម ។ អូរនេះស្ថិតនៅជាប់ព្រំប្រទល់ភូមិតាមាសនិងភូមិតាកែវ ឃុំគរ ហើយក្លាយទៅជាកន្លែងដាក់សាកសពតាំងពីឆ្នាំ១៩៧៥មក ។ លោកពូណៃ គឹមសាន់បានប្រាប់ថាមានសាកសពប្រហែល១០០០នាក់ត្រូវបានពួកខ្មែរក្រហមសម្លាប់ រួចយកមកគំរៀបក្នុងអូរនេះដែលមានជំរៅ១ម.និងទទឹងពី២-២,៥ម. ។ លោកពូបន្តទៀតថាសាកសពទាំងនោះមិនបានកប់ដីពីលើទេ ។ អ្នកដែលបានស្លាប់ក្នុងអូរនេះច្រើនតែជាអ្នកជាប់និន្នាការ និងកម្មាភិបាលខ្មែរក្រហមដែលបានខុសសីលធម៌ ។ បច្ចុប្បន្នអូរស្ងួតទឹកសំរាប់ធ្វើស្រែ ។

ខ. ទួលក្រសាំងៈ

ស្ថិតនៅក្នុងទឹកដីភូមិតាកែវ, ឃុំគរ ។ ទួលនេះមានទំហំ៥០៖១០០ម. ហើយបច្ចុប្បន្នមានដើមក្រសាំងជាសំគាល់ ។ តាមសំដីលោកពូណៃ គឹមសាន់ថាកាលពីសម័យប៉ុល ពតខ្មែរក្រហមកាន់អំណាចទួលនេះជាទួលសម្លាប់មនុស្សនិងកប់មនុស្សជាច្រើននាក់ ។ មានរណ្តៅច្រើនណាស់នៅលើទួលនេះ តាមការប៉ាន់ស្មានរបស់គឹមសាន់ថាមានដល់ទៅរាប់រយរណ្តៅឯណោះ ហើយចំនួនសាកសពមានចំនួនរហូតដល់ទៅជិត១០០០នាក់ដូចទីតាំងអូរតាគងដែរ ។ លោកពូបន្ថែមថាក្នុងមួយរណ្តៅៗមានសាកសពពី៣-៥នាក់ ។ ទីតាំងនេះស្ថិតនៅខាងលិចគុកសន្តិសុខមិត្តសុបប្រហែល៥០០ម. និងស្ថិតនៅខាងលិចឈៀងខាងជើងទីតាំងអូរតាគង ។

គ. ត្នោតជួរៈ

ទីតាំងនេះក៏ស្ថិតនៅក្នុងភូមិតាកែវ ឃុំគរដែរ ប៉ុន្តែស្ថិតនៅទិសខាងត្បូងទីតាំងអូរតាគង់ប្រហែលជា ៥០០ម. និងមានចំងាយប្រហែល២០០ម.ពីមន្ទីរសន្តិសុខមិត្តសុប ។ ទួលគ្មោតជួរមានទំហំដីប្រមាណ២០០ម. បួនជ្រុងដែលមានពី៧០-៨០រណ្តៅ ហើយក្នុងមួយរណ្តៅៗមានជំរៅពី២-៣ម. និងមានទំហំ២ម.បួនជ្រុង ។ ណៃ គឹមសាន់បញ្ជាក់ថា សាកសពដែលបានស្លាប់នៅទីនោះមានប្រហែលជាពី២៤០-៣០០នាក់ ។

ឃ. ទួលដើមអំពិលៈ

ទួលនេះស្ថិតនៅក្នុងភូមិតាកែវ ឃុំគរជាប់នឹងព្រំប្រទល់ភូមិតាមាស ។ ទីតាំងនេះនៅជាប់ជាមួយនិងទីតាំងអូរតាគង់តែម្តង, បច្ចុប្បន្នមានដើមអំពិលជួរមួយដើមជាសំគាល់ ។ ណៃ គឹមសាន់និយាយថាមាន២០រណ្តៅ ក្នុងមួយរណ្តៅៗមានទំហំ២៖៣ម. ដែលមានផ្ទុកសាកសពពី៣-៤នាក់ ។ លោកពូគឹមសាន់ក៏បានធ្វើការសន្និដ្ឋានថារណ្តៅទាំង២០នេះមានសាកសពសរុបប្រហែល៨០នាក់ ។

ង. ទីតាំងសម្លាប់នៅក្នុងសាលាបឋមសិក្សាប៊ុន រ៉ានីហ៊ុនសែន ឃុំគរៈ

ស្ថិតនៅក្នុងភូមិតាម៉ូត ឃុំគរ ស្រុកព្រៃឈរ ។ កាលពីជំនាន់សីហនុ ក៏ជាសាលាបឋមសិក្សាដែរ ហើយរហូតមកដល់ជំនាន់ប៉ុល ពតសាលានេះក៏ក្លាយជាកន្លែងសម្លាប់មនុស្សនិងកប់មនុស្សជាច្រើនរយនាក់ ។ អាគារមួយខ្នងស្ថិតនៅខាងមុខគេក្នុងចំនោមអាគារទាំងបីខ្នងទន្ទឹមគ្នាប៉ែកខាងកើត កាលពីឆ្នាំ១៩៧៥-៧៩ជាអាគារសំរាប់ស្តុបអ្នកទោសនិងសម្លាប់អ្នកទោស ។ ក្រោយពីបែកឆ្នាំ១៩៧៩អាគារមួយខ្នងនេះនៅមានស្នាមឈាមប្រឡាក់ជញ្ជាំងព្រមទាំងមាននៅសេសសល់នូវវត្ថុតាងសំរាប់សម្លាប់អ្នកទោសដូចជាដំបងជង ប៉ុន្តែយ៉ាងហោចណាស់ក៏ធ្វើអោយមនុស្សវ័យចំនាស់ៗភាគច្រើនដែលក្នុងភូមិ ឃុំខាងលើនៅតែនឹកឃើញនូវការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃរបស់ពួកខ្មែរក្រហមមកលើប្រជាជនស្លូតត្រង់កាលពីឆ្នាំ១៩៧៥-៧៩ដែរ ។ ជាក់ស្តែងលោកណៃ គឹមសាន់បាននាំក្រុមយើងទៅមើលផ្ទាល់ដល់អាគារមួយខ្នងនេះ ព្រមទាំងបានរៀបរាប់ប្រាប់យើងពីការសម្លាប់មនុស្សនាពេលនោះ(១៩៧៥-១៩៧៩) នៅក្រោយឆ្នាំ១៩៧៥ប្រជាជនត្រូវពួកខ្មែរក្រហមជំលៀសចេញអោយនៅភូមិផ្សេងៗ ហើយយកប្រជាជនថ្មី(១៧មេសា) មកដាក់ជំនួសវិញ ពិសេសនៅភូមិភាគតាកែវនិងភូមិភាគតាមាស ។ ការស្នាក់នៅនៃប្រជាជនថ្មីទាំងនោះមិនបានយូរឡើយ គឺត្រូវពួកខ្មែរក្រហមដឹកទាំងយប់(ម៉ោង១២យប់)មកកាន់សាលាបឋមសិក្សានេះរួចហើយក៏ធ្វើការសម្លាប់តែម្តង ។ ប្រជាជនដែលបានដឹកមកកាន់សាលានេះសុទ្ធតែត្រូវចាញ់បោកពាក្យឃោសនារបស់ខ្មែរក្រហមថាឲ្យមកប្រជុំ ។ ក្រោយពីការសម្លាប់សាកសពទាំងនោះត្រូវបានពួកខ្មែរក្រហមអូសយកមកដាក់ក្នុងបគ្គន់មួយដែលស្ថិតនៅខាងជើងអាគារ(ដែលពួកខ្មែរក្រហមយកធ្វើជាកន្លែងសម្លាប់មនុស្សកាលនៅកាន់កាប់)ប្រហែលជា១០០ម. ។ ជនដៃដល់ក្នុងការសម្លាប់ប្រជាជនកាលនោះឈ្មោះតែមនិងឈ្មោះដន ។ ចំនួនសាកសពក្នុងបគ្គន់នេះលោកពូណៃ គឹមសាន់បានបញ្ជាក់ថាមានចំនួនប្រហែលជា២០០នាក់(បូករួមទាំងក្នុងបន្ទប់បគ្គន់និងលូរបគ្គន់) ។ ចំនែកឯបរិវេណជិតៗបគ្គន់ជាពិសេសប៉ែកខាងលិចបគ្គន់ ក៏មានរណ្តៅច្រើនផងដែរ ដូចលោកពូណៃ គឹមសាន់និយាយថាមានរណ្តៅចំនួន៦០ក្នុងទំហំដីជាង១០០ម. ។ រណ្តៅនីមួយៗមានទំហំ១៖២ម. ជំរៅ១ម. ជីកជាបីជួរ(ក្នុងមួយជួរមាន២០រណ្តៅ) ។ សាកសពសរុបទាំង៦០រណ្តៅនេះមានចំនួនប្រហែល២៥០នាក់ ។

លោកពូណៃ គឹមសាន់ក៏បានបញ្ជាក់ផងដែរពីករណីទីវ មុីដែលត្រូវពួកខ្មែរក្រហមយកទៅសម្លាប់។ ទីវ មុី ត្រូវពួកខ្មែរក្រហមយកទៅសម្លាប់នៅខែ៣ ៤ឆ្នាំ១៩៧៥ដោយចោទថាជាអ្នករដ្ឋការចាស់។ លោកពូនិយាយថាពេលដែលខ្មែរក្រហមមកចាប់ទីវ មុីនៅពេលព្រលប់រួចបណ្តើរគាត់តាមសាលារៀនបឋមសិក្សាខាងលើស្រាប់តែទីវ មុី ស្រែកថា «អាមុីកូនជាងឃឹមគេយកទៅសម្លាប់ហើយ»។ សម្រែករបស់ទី មុី ០វានធ្វើឲ្យជនរងគ្រោះដទៃទៀតតក់ស្លុតយ៉ាងខ្លាំង។ តាមសំដីរបស់លោកពូ ណៃ គឹមសាន់ ថាឈ្មោះ តែម ជាជនដៃដល់ក្នុងការសម្លាប់ទីវ មុី។ គាត់បានបន្តថា ទីវ មុី បានទាញគ្រាប់បែក(ផ្លែទឹកដោះ) បម្រុងគប់ទៅលើពួកខ្មែរក្រហមដែលមកចាប់ ទីវ មុី ប៉ុន្តែមិនទាន់បានគប់ផង ក៏ត្រូវទាហានខ្មែរក្រហមចាប់បាន។ ណៃ គឹមសាន់ថាពេលខ្មែរក្រហមបណ្តើរ ទីវ មុីទៅសម្លាប់ស្រាប់តែ ទីវ មុីទាត់ពួកខ្មែរក្រហមម្នាក់ស្លាប់។

ក្នុងពេលដដែលនោះ ក្រុមយើងបានជួបជាមួយលោកនាយករងសាលាបឋមប៊ុនរ៉ានីហ៊ុនសែនឃុំគរឈ្មោះ ហោ គឹមសុង។ លោកនាយករងបានប្រាប់ថានៅក្នុងបរិវេណសាលានេះ ជាពិសេសនៅត្រង់បង្គន់និងជិតបង្គន់ មានការសម្លាប់ទាហានលន់ណុលដែលបានចុះចូលជាមួយនឹងខ្មែររំដោះ(ខ្មែរក្រហម) នៅបន្ទាយតាំងគោកកាលពីឆ្នាំ១៩៧៣។ ឪពុកមាររបស់លោកនាយករងបានប្រាប់គាត់ថាពួកខ្មែរក្រហមបានចាប់ផ្តើមសម្លាប់ទាហានលន់ណុលនៅក្នុងបរិវេណសាលានេះតាំងពីឆ្នាំ១៩៧១មកម្ល៉េះ។ ទាហានដែលបានស្លាប់នៅកន្លែងនេះតាំងពីឆ្នាំ ១៩៧១-១៩៧៤មានចំនួនប្រហែលរាប់ពាន់នាក់។ វិធីសម្លាប់របស់ខ្មែរក្រហមនៅពេលនោះគឺប្រើការ៉េះគោជាឧបករណ៍សម្លាប់។ ម៉ោងប្រហែល៦-៧យប់ជាពេលដែលខ្មែរក្រហមយកទាហានមកសម្លាប់។

នៅវេលាម៉ោង១១:៤០នាទីព្រឹក ក្រុមយើងបានចាកចេញពីសាលាបឋមសិក្សាប៊ុនរ៉ានីហ៊ុនសែនឃុំគរ និងទីតាំងសម្លាប់ទាំង៤ខាងលើឆ្ពោះទៅកាន់ផ្សារដើម្បីបរិភោគអាហារថ្ងៃត្រង់។ បន្ទាប់ពីបរិភោគអាហាររួចក្រុមយើងបានបន្តដំណើរទៅកាន់ទីតាំងមួយកន្លែងទៀតដែលស្ថិតនៅក្នុងឃុំថ្មពូន ស្រុកព្រៃឈរដែរ។

មន្ទីរសន្តិសុខស្រុក៧៧លើ

ក្រោយពីបានអង្គុយលេងជាមួយប្រធាននគរបាលឃុំថ្មពូនក្នុងទីស្នាក់ការនគរបាលប៉ុស្តិ៍ថ្មពូនអស់រយៈជិតមួយម៉ោងមក យើងបានជួបជាមួយលោកជំនួយការឃុំថ្មូនឈ្មោះ ងិន ណារី។ ណារី មានអាយុ៣៨ឆ្នាំ មានអាស័យដ្ឋានទាំងបីជំនាន់រស់នៅក្នុងភូមិអណ្តូងតាពេជ្រ ឃុំថ្មពូន ស្រុកព្រៃឈរ។ លោកពូមានប្រសាសន៍ថានៅក្នុងឃុំថ្មពូនមានទីតាំងគុកសន្តិសុខមួយកន្លែង និងទីតាំងសម្លាប់មួយកន្លែងដែរគឺស្ថិតនៅខាងកើតសាលាឃុំថ្មពូនប្រហែល១៥០ម៉ែត្រ។ កាលពីដើមឡើយមន្ទីរសន្តិសុខនេះគឺជាផ្ទះរបស់ប្រជាជនម្នាក់ឈ្មោះ អ៊ឹម ចន (បច្ចុប្បន្នស្លាប់)។ ផ្ទះ អ៊ឹម ចន បានក្លាយទៅជាមន្ទីរសន្តិសុខតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ។ ប្រភេទជនរងគ្រោះដែលបានជាប់នៅក្នុងមន្ទីរនេះច្រើនជាអ្នកខុសសីលធម៌ ទាហានលន់ណុល...។ល។ មន្ទិរនេះត្រូវរលាយទៅវិញនៅឆ្នាំ១៩៧៨ ហើយក៏ក្លាយទៅជាកន្លែងចិញ្ចឹមគោវិញ។ អ្នកគ្រប់គ្រងមន្ទីរនេះមានពីរនាក់គឺ ភិន និង ថាន់។ ភិន គ្រប់គ្រងតាំងពីឆ្នាំ១៩៧៣-៧៦ ឯចំណែក ថាន់វិញគ្រប់គ្រងបន្តពី ភិន រហូតដល់ឆ្នាំ១៩៧៨។

ទីតាំងសម្លាប់អណ្តូងតាផាន់

ស្ថិតនៅខាងកើតឈៀងខាងត្បូងប្រហែល១៥០ម៉ែត្រពីមន្ទីរសន្តិសុខស្រុក៧៧លើ ។ ទីតាំងនេះគ្មានរណ្តៅទេ មានតែអណ្តូងមួយឈ្មោះថាអណ្តូងតាផាន់ ។ អណ្តូងនេះ លោកណារី មិនអាចសន្និដ្ឋានពីទំហំនឹងជំរៅបានទេ ប៉ុន្តែលោក ណារី បាននិយាយថាមានមនុស្សស្លាប់ប្រហែល១០០នាក់នៅក្នុងអណ្តូងនេះ ។

ស្រុកបាធាយ

១)មន្ទីរសន្តិសុខវត្តប្រើសមាស

យោងតាមចម្លើយរបស់អ្នកដឹងហេតុការណ៍ច្បាស់ចំនួនពីរនាក់គឺ ញឹប ញៀប ជាប្រជាជនរស់នៅក្នុងភូមិថ្កូវ ឃុំត្រប់ ស្រុកបាធាយនឹងលោកមាច ផាញ់ អាយុ៥៣ឆ្នាំ ជាមេឃុំត្រប់ថា មានមន្ទីរសន្តិសុខមួយកន្លែងស្ថិតនៅក្នុងបរិវេណវត្តប្រើសមាស ។ កុដិមួយដ៏ធំនៃវត្តប្រើសមាសត្រូវបានពួកខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងមនុស្សនិងធ្វើទារុណកម្មមនុស្សតាំងពីឆ្នាំ១៩៧៦មក ។ សព្វថ្ងៃកុដិមួយនេះមិនត្រូវបានកម្ទេចចោល ឬកែទម្រង់ថ្មីឡើយ ។ ចំពោះការធ្វើទារុណកម្ម និងសម្លាប់ពួកខ្មែរក្រហមច្រើនយកដំបង កាំបិត ត្បូងចបមកធ្វើជាឧបករណ៍ ។ អ្នកទោសដែលជាប់ក្នុងមន្ទីរឃុំឃាំងនេះច្រើនជាប្រជាជនថ្មី អ្នកខុសសីលធម៌ព្រមទាំងប្រជាជនចាស់ខ្លះដែលបានលួចដំឡូងជាដើម ។

២)ទីតាំងសម្លាប់

លោកមេឃុំត្រប់ និង ញឹប ញៀប បានប្រាប់ថាជុំវិញបរិវេណមន្ទីរសន្តិសុខវត្តប្រើសមាសមានបីទីតាំងគឺៈ

- ចម្ការតាតាំងៈ ស្ថិតនៅក្នុងភូមិត្រប់ ឃុំត្រប់ ស្រុកបាធាយ ។ មានបួនរណ្តៅដែលមានទំហំពីរម៉ែត្រទទឹង និងបួនម៉ែត្របណ្តោយក្នុងរណ្តៅមួយៗ ។ អ្នកស្លាប់មានពី២០-៣០នាក់ ។
- ខាងកើតវត្តប្រើសមាសៈ មានពីររណ្តៅដែលាមនទំហំ២ម៉ែត្រទទឹងនិង៤ម៉ែត្របណ្តោយ ។សាកសពរួមមានប្រហែលជាង១០នាក់ ។
- ខាងក្នុងខ្លោងទ្វារវត្តប្រើសមាសៈ មានតែមួយរណ្តៅទេដែលមានសាកសព៣នាក់ ។ ទំហំរណ្តៅ២ម៉ែត្រទទឹងនិង៤ម៉ែត្របណ្តោយ ។

មេឃុំត្រង់ក៏បានបញ្ជាក់ដែរថា នៅក្នុងឃុំត្រង់ បើយោងទៅតាមការស្រង់ស្ថិតិអ្នកស្លាប់តាមគ្រួសារមានចំនួនដល់ទៅ១៥០០នាក់ ប៉ុន្តែលោកមេឃុំបន្តទៀតថា អ្នកទាំង១៥០០នាក់នោះមិនមែនស្លាប់នៅក្នុងឃុំត្រប់នេះតែមួយកន្លែងទេ គឺត្រូវបានពួកខ្មែរក្រហមដឹកទាំងឡានៗទៅសម្លាប់ចោលនៅភ្នំប្រុសភ្នំស្រីអស់មួយចំនួនធំ ។ មេឃុំរូបនោះក៏បានបន្ថែមថា នោមានទីតាំងសម្លាប់មួយទៀតឈ្មោះថា ទួលភ្លើងឆេះ ហៅថា ទួលប្រាសាទចាម

ដែលស្ថិតនៅក្នុងភូមិភ្នំតូច ឃុំគ្រប់ ។ ទីតាំងនេះជាទីតាំងសម្លាប់មួយក្នុងឃុំគ្រប់ដែលមានមនុស្សស្លាប់ប្រហែល ១០០នាក់ ។ ប្រជាជនដែលបានមកស្លាប់នៅទីនេះ លោកមេឃុំប្រាប់ថាច្រើនជាប្រជាជន១៥មេសា ។

បន្ទាប់ពីបញ្ចប់កិច្ចសម្ភាសន៍ជាមួយលោកមេឃុំគ្រប់ និងញ៉ិប ញៀបមក ក្រុមយើងបានបន្តដំណើរទៅពិនិត្យជាក់ស្តែងនូវអំពីទីតាំងទាំងប៉ុន្មានខាងលើព្រមទាំងមន្ទីរសន្តិសុខមួយផង ។ ជាចុងក្រោយយើងបានទៅពិនិត្យទីតាំងទួលប្រាសាទចាមទៀត ។ នៅក្បែរទួលនេះប្រហែល២០០ម៉ែត្រ យើង០ានជួបជាមួយលោកតាម្នាក់ជាប្រជាជនដែលរស់នៅក្នុងភូមិតាព្រង ឃុំគ្រប់ ស្រុកបាធាយ ។ គង់ យិន ជាឈ្មោះរបស់លោកតានោះ គាត់មានអាយុ៦៧ឆ្នាំ ។ លោកតាបានប្រាប់យើងដូចលោកមេឃុំប្រាប់ដែរប៉ុន្តែលោកតាបានបន្ថែមថាការសម្លាប់មនុស្សនៅទួលប្រាសាទចាមនេះធ្វើឡើងនៅចុងឆ្នាំ១៩៧៥ ។ អ្នកទោសច្រើនបណ្តើរមកទាំងខ្សែៗដោយមានចងស្លាបសេក និងដោតខ្សែក្រោមឃៀកជាជួរៗ ។ ក្នុងមួយជួរៗ លោកតាប្រាប់ថាមានចំនួនពី២៥ទៅ៣០នាក់ ហើយបណ្តើរម្តងៗមានពីបីទៅបួនខ្សែមកសម្លាប់នៅទីតាំងនេះ ។ អ្នកទោសទាំងនោះភាគច្រើនជាប្រុសៗ ។ លោកតាក៏បានបញ្ជាក់ដែរថា ទីតាំងនេះក៏មានសម្លាប់ទាហានលន់ណុលដែរ ដែលពួកទាហានខ្មែរក្រហមចាប់បាននៅក្នុងសង្គ្រាមនៅព្រៃគ្រីខេត្តកំពង់ឆ្នាំង ។ អ្នកណ្តើរប្រជាជនមកសម្លាប់ឈ្មោះ ស្រ៊ិន, ឡូន, និងថេន ។ នៅទួលប្រាសាទចាមមានរហូតដល់ទៅ១៥ទៅ១៦រណ្តៅ ហើយក្នុងមួយរណ្តៅៗមានដាក់សាកសពពី២-៣នាក់ ។ វិធីសម្លាប់របស់ពួកខ្មែរក្រហមមកលើអ្នកទោសគឺដំបង, ត្បូងចប, គល់ឫស្សី, ដាវ.....។ល ។ សាកសពរួមនៅទួលប្រាសាទចាម លោកតាបានប្រាប់ដូចលោកមេឃុំដែរថាមានចំនួនប្រហែល១០០នាក់ ។

ទីតាំងដែលពុំទាន់បានធ្វើការស្រាវជ្រាវ

មានមួយកន្លែងស្ថិតនៅក្នុងភូមិរំដួល ជាប់ព្រំប្រទល់ភូមិគោកស្រឡៅ ឃុំបារាយណ៍ ស្រុកព្រៃឈរ ។ យោងតាមសម្តីរបស់លោក ណៃ គឹមសាន់ ថា ទីតាំងនេះជាទីតាំងសម្លាប់ដែលមានចម្ងាយជាង១គីឡូម៉ែត្រពីផ្លូវថ្នល់ ។ យើងមិនអាចធ្វើដំណើរទៅដល់ទេ ព្រោះគ្មានផ្លូវសុទ្ធតែជាស្រែរបស់ប្រជាជន ។ គឹមសាន់ ប្រាប់ថា ទីតាំងនេះមានវៃប្រជាជនជាអ្នកជាប់និន្នាការ ទាហាន តាំងពីឆ្នាំ១៩៧៥ ។ ខ្មែរក្រហមបានវៃប្រជាជនទាំងនោះទម្លាក់ទៅក្នុងអណ្តូងមួយដែលមានអង្កត់ផ្ចិត១ម៉ែត្រ ជម្រៅ៦-៧ម៉ែត្រ ។ អណ្តូងនោះមានចំនួនជាង១០០នាក់ ។

សន្និដ្ឋាន

ក្នុងដំណើរចុះទៅកាន់ខេត្តកំពង់ចាមលើកនេះ ជាពិសេសនៅស្រុកចំការលើ ព្រៃឈរ និងបាធាយ អាចចាត់ទុកថាបានទទួលលទ្ធផលល្អ ព្រោះយើងបានជួបសម្ភាសន៍ជាមួយអ្នកដឹងឮច្រើន និងបានចុះទៅដល់ទីតាមផ្ទាល់ស្ទើរតែគ្រប់ទីតាំង ។ នេះក៏មកពីយើងមានពេលវេលាគ្រប់គ្រាន់ ដ៏ដូចជាមានការអភិវឌ្ឍទៅលើផ្លូវធ្វើដំណើរពីមុន (១៩៩៧-៩៩) មិនមែនជាផ្លូវពេញលក្ខណៈ ហើយបច្ចុប្បន្នក្លាយជាផ្លូវមួយដ៏ស្អាតក្រោមការស្ថាបនារបស់អង្គការអភិវឌ្ឍន៍ជនបទ ។

ចំពោះបញ្ហាសន្តិសុខវិញ គ្មានអ្វីចោទជាបញ្ហាទេ មានតែការសហការល្អពីបណ្ដាប្រជាជនក៏ដូចជាមន្ត្រីសាលាខេត្ត ស្រុក ឃុំ និងភូមិដែរ ។ រាល់ការចុះទៅដល់ទីតាំងមួយៗសុទ្ធតែមានការជូនដំណើរពីមន្ត្រីគ្រប់ជាន់ថ្នាក់ ។

បញ្ហាសំខាន់មួយទៀតសម្រាប់ក្រុមស្រាវជ្រាវយើង គឺយើងមានការស្គាល់ច្រើនពីមន្ត្រីថ្នាក់ឃុំ ស្រុក ខេត្ត នេះក៏ព្រោះតែយើងមានទស្សនាវដ្ដីស្វែងរកការពិតដែលទើងតែបានចាប់បដិសន្ធិនៅដើមឆ្នាំ២០០០ ហើយត្រូវបានចែកជូនដោយឥតគិតថ្លៃដល់បណ្ដាខេត្ត ស្រុក ឃុំទូទាំងប្រទេសកម្ពុជា ។ ក្រុមស្រាវជ្រាវយើងហាក់មានមោទនៈភាពខាំងនៅពេលដែលប្រាប់ទៅគេថា ធ្វើការបម្រើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយត្រូវបានទទួលមកវិញនូវភាពរស់រាយ រាក់ទាក់ និងសហករណ៍យ៉ាងអស់ពីចិត្តរវាងមន្ត្រីគ្រប់ជាន់ថ្នាក់ ។

ក្រុមស្រាវជ្រាវយើងសង្ឃឹមថានៅពេលចុះទៅបណ្ដាខេត្តផ្សេងៗទៀត ពិតជាបានទទួលបាននូវការសហករណ៍ល្អដូចនៅខេត្តកំពង់ចាមដែរ ។

ចំពោះសាក្សីដែលបានដឹងរឿងរ៉ាវនាសម័យខ្មែរក្រហម សុទ្ធតែបានផ្ដល់នូវចម្លើយយ៉ាងស្មោះត្រង់ដល់ក្រុមយើង ។

Kampong Cham province:

District	Site Name / Visit Date	Site Type	Est. Victim	Witness	File #/ID Code	Latitude	Longitude
Chamkar Leu	Chamkar Svay Chanty May 24,2000	Prison & Burial Site	5000-7000	Mam Sarun ម៉ម សារុន	R052407A/ 030207	N12^{0}17'2612"	E105^{0}16'3185"
Chamkar Leu	Chamkar Svay Chanty May 24,2000	Burial Site	5000-7000	Long Sokhai ឡុង សុខៃ	R052407B/ 030208	N12^{0}17'3731"	E105^{0}16'3145"
Chamkar Leu	Lo M-18 May 25,2000	Burial Site	More than 500 families 1,500	Saom Ly សោម លី	R052505A/ 030209	N12^{0}13'0643"	E105^{0}18'5054"
Chamkar Leu	Lo M-18 May 25,2000	Burial Site	Several thousands	Say Ry សាយ រី	R052505B/ 030210	N12^{0}12'5826"	E105^{0}18'4453"
Prey Chhor	O Ta Kong May 26,2000	Burial Site	About 1000	Nai Kim Sann ណៃ គីម សាន់	R052601A/ 031303	N12^{0}07'0594"	E105^{0}12'1902"
Prey Chhor	Toul Kra Saing May 26,2000	Burial Site	About 1000	Nai Kim Sann ណៃ គីម សាន់	R052602A/ 031304	N12^{0}07'0081"	E105^{0}12'0820"
Prey Chhor	Tnaot Chour May 26,2000	Burial Site	240-300	Nai Kim Sann ណៃ គីម សាន់	R052602B/ 031305	N12^{0}06'5149"	E105^{0}12'1846"
Prey Chhor	Comrade Sup' s prison May 26,2000	Prison	N/A	Nai Kim Sann ណៃ គីម សាន់	R052603A/ 031306	N12^{0}06'5820"	E105^{0}12'2243"
Prey Chhor	Preliminary School "Kor" May 26,2000	Burial Site	About 250	Nai Kim Sann ណៃ គីម សាន់	R052603B/ 031307	N12^{0}06'4717"	E105^{0}12'5246"
Prey Chhor	Ta Phann' s water well May 26,2000	Burial Site	About 100	Nai Kim Sann ណៃ គីម សាន់	R052607A/ 031308	N12^{0}08'5415"	E105^{0}14'4123"
Prey Chhor	District 77 Leu' s prison May 26,2000	Prison	N/A	Ngin Navy ងិន ណាវី	R052607B/ 031309	N12^{0}08'5993"	E105^{0}14'3547"
Bateay	Toul Ta San May 27,2000	Burial Site	30-40	Nhoek Nhieb ញឹក ញៀប	R052703A/ 030105	N12^{0}08'1045"	E104^{0}56'5084"
Bateay	Wat Praes Meas May 27,2000	Burial Site & Prison	50-70	Meach Thann មាជ ថាន់	R052703B/ 030106	N12^{0}08'0628"	E104^{0}56'2861"
Bateay	Pra Sat Cham May 27,2000	Burial Site	About 100	Kong Yin គង់ យិន	R052703C/ 030107	N12^{0}07'3993"	E104^{0}56'3262"

Kampong Cham province:

District	Site Name / Visit Date	Site Type	Est. Victim	Witness	File #/ID Code	Latitude	Longitude
Chamkar Leu	Chamkar Svay Chanty May 24,2000	Prison & Burial Site	5000-7000	Mam Sarun ម៉ម សារុន	R052407A/ 030207	N12^{0}17'2612"	E105^{0}16'3185"
Chamkar Leu	Chamkar Svay Chanty May 24,2000	Burial Site	5000-7000	Long Sokhai ឡុង សុខៃ	R052407B/ 030208	N12^{0}17'3731"	E105^{0}16'3145"
Chamkar Leu	Lo M-18 May 25,2000	Burial Site	More than 500 families	Saom Ly សោម លី	R052505A/ 030209	N12^{0}13'0643"	E105^{0}18'5054"
Chamkar Leu	Lo M-18 May 25,2000	Burial Site	Several thousands	Say Ry សាយ រី	R052505B/ 030210	N12^{0}12'5826"	E105^{0}18'4453"
Prey Chhor	O Ta Kong May 26,2000	Burial Site	About 1000	Nai Kim Sann ណៃ គីម សាន់	R052601A/ 031303	N12^{0}07'0594"	E105^{0}12'1902"
Prey Chhor	Toul Kra Saing May 26,2000	Burial Site	About 1000	Nai Kim Sann ណៃ គីម សាន់	R052602A/ 031304	N12^{0}07'0081"	E105^{0}12'0820"
Prey Chhor	Tnaot Chour May 26,2000	Burial Site	240-300	Nai Kim Sann ណៃ គីម សាន់	R052602B/ 031305	N12^{0}06'5149"	E105^{0}12'1846"
Prey Chhor	Comrade Sup' s prison May 26,2000	Prison	N/A	Nai Kim Sann ណៃ គីម សាន់	R052603A/ 031306	N12^{0}06'5820"	E105^{0}12'2243"
Prey Chhor	Preliminary School "Kor" May 26,2000	Burial Site	About 250	Nai Kim Sann ណៃ គីម សាន់	R052603B/ 031307	N12^{0}06'4717"	E105^{0}12'5246"
Prey Chhor	Ta Phann' s water well May 26,2000	Burial Site	About 100	Nai Kim Sann ណៃ គីម សាន់	R052607A/ 031308	N12^{0}08'5415"	E105^{0}14'4123"
Prey Chhor	District 77 Leu' s prison May 26,2000	Prison	N/A	Ngin Navy ងិន ណាវី	R052607B/ 031309	N12^{0}08'5993"	E105^{0}14'3547"
Bateay	Toul Ta San May 27,2000	Burial Site	30-40	Nhoek Nhieb ញឹក ញៀប	R052703A/ 030105	N12^{0}08'1045"	E104^{0}56'5084"
Bateay	Wat Praes Meas May 27,2000	Burial Site & Prison	50-70	Meach Thann មាជ ថាន់	R052703B/ 030106	N12^{0}08'0628"	E104^{0}56'2861"
Bateay	Pra Sat Cham May 27,2000	Burial Site	About 100	Kong Yin គង់ យិន	R052703C/ 030107	N12^{0}07'3993"	E104^{0}56'3262"

From: YANNEEDO@aol.com <YANNEEDO@aol.com>
To: dccam@bigpond.com.kh <dccam@bigpond.com.kh>
Date: Monday, April 17, 2000 10:05 AM
Subject: Comment

To : Mr. Chhang,
As a survivor of killing field,I admire your courage to document the crime against humanity executed by regime of DK.If you could,I would provide you some useful information about KE POK and his family who run the northern zone.I was living in the village of Thnal Bek keut(two Thnal bek east and west) Sangkat Svay Teap,Srok Chamkar Leu,Kg.Cham.The entire "new people" in this village were executed,exept my family and my friend now living in Boston,Ma. My house and my friend were located not far from headquarter (monti phoum pheak) resided by KE POK,the distance approximately one bloc.During the harsh labor we used to walk in front of his residence almost everyday.After Koy Thuon was purged this guy became a head of Northern Zone and his brother-in-law named (mit OEUN) became a chief of Tambon KE POK's wife named OEUN played important role with her husband,she used to travel to oversea with Pol Pot's wife.Since there were a lot of new people settled in this village close to his residence,the chief of village must smashed them all and taking all the victime belongings to KE POK's residence to show a good faith that he or she was really loved and honest to the Angkar especially Angkar Pheak located close to this village.During 1978,four or five months prior to the arrival of invading troup from vietnam,I estimated about 5,000.to 10,000.not including the previous killing New people were executed in the field of Svay Chanty about 1 mile west of Svay Teap school,among the victimes one of my another best friend's wife 9 months pregnant and his 6 years old daughter.(my friend now living at Lexington,Ma and engineer for Duracell Company).Why my self and other two friend families were survived,we were sent to work at the field of producing brick about 5 miles north of village.When I came back I counted only two families originating from Phnom Penh were survived,my family and my friend family.We know KE POK very well his hand soaked by blood the same as a DK leader.Also,during that time I used to visit KHIEV SENG KIM, the young brother of KHIEV SAMPHAN.Khiev Seng Kim was a regular farmer the same as everybody,he did not receive any special priviledge from the Angkar at all despite he is a young brother of Angkar.,what I knew his family received periodically some medecine from his mother via Khmer rouge soldier happened to be his nephiew.For him being lazy and make mistake during that time,he was tolerated otherwise he would be killed like the rest of victimes.Again,KE POK,his brother-in-law were really committed the atrocities intentionally.Whatever he denied or put the blame on his boss(POL POT) do not believe this guy.He ordered to kill too many people not in my

village alone,let face the reality he ordered to wipe out the entire khmer islam located
in Speu village about 1 mile north from his house.Me and my fried know this man very well,I do not know the rest of DK leaders.
I am planning to visit this villge next year with my friend .Any further information feel free to e-mail me . Thank

Yannee Doeur
Providence,R.I ,USA

From: YANNEEDO@aol.com <YANNEEDO@aol.com>
To: dccam@bigpond.com.kh <dccam@bigpond.com.kh>
Date: Thursday, April 20, 2000 9:47 PM
Subject: comment

Mr. Youk, thank for your response,
I am very interest in this matter,because I was one of the survivor in
addition both my
parents and my two sibling were killed during 1978 at Prey Kabas
district,Takeo.
I really want to see this trial happen no matter what. I heard you are from
Texas
as you know there are a lot khmer people in the U.S.and they seem not to care
too
much about what you have done because lack of communication and
misunderstanding.Every khmer of live in the U.S at least had one or more in
their family were lost their life in KR regime too.What they're care is to
visit their family or
take vacation in Cambodia.As matter of fact, they live here don't meant they
are not
effective in term of lobby to their respective U.S congrees for all cause
that related to
Cambodia.Cutting short,I would recommend you to take an active role to
promote the
awareness among khmers here how important is what are you doing.the goal is to
seek more funding from government or private institution to support your
organization
Most of my friends in New England area are
professional,lawyer,accountant,Real estate,Doctor,restaurant owner and
Grocery owner etc.. Thank

Khmers rouges

Ke Pauk : quelle implication dans les massacres de Svay Chanty?

En 1978, dans les champs du lieu-dit de Svay Chanty ("noix de cajous"), dans le district de Chamcar Lœu de la province de Kompong Cham, entre 5 000 et 10 000 personnes, en majorité des citadins de Phnom Penh considérés comme "peuple nouveau" par les révolutionnaires, auraient été exécutés par les Khmers rouges, d'après les récits de survivants recueillis récemment par Youk Chhang et Peng Pong Rasy du Centre de documentation du Cambodge. A l'époque, Ke Pauk (de son vrai nom Ke Vin), aujourd'hui général des Fark depuis son ralliement au gouvernement en 1998, était secrétaire de la zone centrale, où ont eu lieu ces massacres, après que son supérieur, Koy Thuon, eut été purgé par le régime en 1977. Son bureau du village de Thnal Bek Kaet, d'où il régnait sur toute la région, n'était situé qu'à 1,5 km de ces champs de la mort.

Quelle a été la responsabilité de Ke Pauk, mais aussi de sa famille, dans ces exécutions de masse? Youk Chhang estime que seul un tribunal indépendant pourra faire la lumière sur la "chaîne de commandement" qui a décidé de cette tuerie. Voici les témoignages sur ce massacre et sur la personnalité de Ke Pauk que lui et son équipe ont pu recueillir sur place :

Yim, désignée comme masseuse de Ke Pauk

La vieille Yim avait été choisie dans la coopérative pour être la masseuse permanente et la sage-femme de la famille de Ke Pauk. Elle s'est faite une idée claire de la personnalité de Pauk, car elle vivait avec lui, sa femme et ses quatre enfants dans le village de Thnal Bek Kaet. Elle vivait dans la terreur d'être tuée, et avait tellement peur de lui et de son épouse, Sœun, dont elle dit qu'elle était la chef du district de Chamcar Lœu, qu'elle n'osait pas regarder son visage. Elle décrit Pauk comme un homme cruel. "A un repas, j'ai vu des gens qui mangeaient avec moi mourir d'empoisonnement", affirme-t-elle. Un jour, Sœun lui dit ceci : "La vieille, tu vis avec moi, tu ne dois pas te faire d'illusions et suivre des étrangers... Si tu fais un travail, tu ne dois faire que cela. Si tu divulgues [des informations] à des étrangers, tu 'tomberas dans l'eau'".

Dœu Yanny et sa famille, comme de nombreuses autres de Phnom Penh, avaient été déportées dans le village en 1975. "Nous connaissions très bien Ke Pauk... Je passais devant sa résidence presque chaque jour", raconte-t-elle. Elle confirme que la femme de Pauk jouait un rôle très important dans les affaires de son mari, et qu'elle voyageait à l'étranger avec l'épouse de Pol Pot. Yanny et ses proches ont survécu au massacre de Svay Chanty en 1978. "Pendant les 5 derniers mois de 1978, j'ai été envoyée avec deux amis façonner des briques à 8 km du village", raconte-t-elle. "A notre retour, il ne restait que deux familles de Phnom Penh, la mienne et celle d'un ami. Quatre ou cinq mois avant l'arrivée des Viêtnamiens, j'ai estimé qu'entre 5 000 et 10 000 victimes reposaient dans les champs de Svay Chanty". Elle pense que le chef de village de Svay Chanty a dû "écraser" la population entière de "gens nouveaux" de la zone en signe de foi et de loyauté envers l'*Angkar pheak* (la zone de l'*Angkar*).

Long Sokhay, 51 ans, était une "personne de base". Il a survécu parce que son nom n'était pas sur la liste de ceux qui devaient se présenter à une "réunion". Un jour, en juin ou juillet 1978, on lui a ordonné de transporter du bois en charrette à bœufs à Chamcar Andaung, une autre coopérative du district. Sur sa route, Sokhay vit de nombreuses familles d'autres villages se diriger à pied et à charrettes à bœufs vers les champs de Svay Chanty. Cela l'intrigua, mais il ne questionna personne et poursuivit sa route. Au retour, Sokhay entendit de bruyants haut-parleurs à Svay Chanty, et sentit que quelque chose d'inhabituel se passait. La nuit précédente, il avait été chargé par des cadres de monter la garde à l'ouest de Svay Chanty. Pendant toute la nuit, on entendait creuser. Sokhay en conclut que les gens qu'il avait vus - qu'il estime à plus de 10 000 - y ont été tués.

Chhun La, du "peuple ancien", était dans les environs de Svay Chanty à l'époque. En juillet 1978, son chef de groupe lui ordonna d'y transporter deux "personnes nouvelles". Sur le chemin, il vit 30 à 40 charrettes à bœufs remplies de familles. A une bifurcation, deux *chlop* ("espion") khmers rouges les ont arrêtées, les obligeant à se rendre aux champs de Svay Chanty. Chhun La vit un des deux cadres, "camarade Suon", ordonner à ses hommes d'attacher les gens dans les charrettes à bœufs. Après, les Khmers rouges leur ont hurlé de tirer par terre les gens qu'ils transportaient. Les biens de valeur furent pris par les cadres, tandis que les valises et les vêtements furent brûlés. Chhun La vit un Khmer rouge armé d'une hache à longue lame et à courte poignée. Les cadres forcèrent les femmes à uriner devant eux, dans leurs *sarong*, et leur donnaient parfois des coups de pieds. A Svay Chanty, Chhun La affirme avoir entendu Ke Pauk dire : "Qui a permis de tuer?... Qui a fait ça?" Mais fin 1978, Pauk a donné l'ordre de dresser une liste des gens éduqués. Cette fois-ci, il dit : "Les éduqués doivent être en haut de la liste parce qu'ils étaient la classe exploiteuse..." Chhun La suspecta quelque chose, et réussit à enlever son nom de la liste grâce à l'aide de la vieille Yim, proche de Ke Pauk.

Tœng Yat, actuel chef du sous-district de Svay Tiep, assure avoir vu juste après la libération 3 fosses communes, de 2m de large sur 30m de long, 2 cratères de bombes de 10m de diamètre, et une tranchée militaire de 2m de large, 100m de long et 1,5m de profondeur. Il estime qu'entre 5 000 et 7 000 victimes ont été enterrées là.

Dœu Yanny prévient que si Ke Pauk et son beau-frère, Œun (chef de la région 303), nient leurs actes ou essaient de mettre cette responsabilité sur Pol Pot, il ne faut pas les croire : "Pauk a ordonné la mort de beaucoup de gens". Long Sokhay a été témoin des préparatifs du massacre à Svay Chanty, et sur le site, Chhun La vit des cadres tourmenter des femmes et se servir d'un outil utilisé habituellement par les Khmers rouges pour tuer les gens. Tœng Yat a vu les restes de 5 000 à 7 000 victimes sur le site en 1979. Mais Chhun La a entendu Ke Pauk dire "Qui a permis de tuer?", et deux jours après, il a donné l'ordre d'exécuter son subordonné, le camarade Yun...

Connaîtra-t-on jamais l'implication exacte de Ke Pauk dans le massacre de Svay Chanty?

Contribution du Centre de documentation du Cambodge (DC-Cam)